គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL

ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២

# សេចក្ដីប្រកាសព័ត៌មាន

## ស្ដីពី

## លទ្ធផលសិក្ខាសាលាសម្លេងម្ចាស់ឆ្នោត ឃុំខ្ចុំក្រាំង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

ដោយមានការគាំទ្រពីគណៈកម្មាធិការខុមហ្វ្រែល សហការជាមួយនឹង សមាគមអាដហុក បានរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតមួយ ស្ដីពី **ការកំណត់តម្រូវការជាអាទិភាពក្នុងឃុំ-សង្កាត់ដាច់ស្រយាល** ដែលធ្វើឡើងនៅឃុំ**ខ្ចុំក្រាំង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ** កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១២។ មានអ្នកមានសិទ្ធិបោះឆ្នោតប្រមាណ ៦៣នាក់(៣១%ជាស្ត្រី) មកពីគ្រប់ភូមិក្នុងឃុំ ដែលរួមមានតំណាងសហគមន៍ តំណាងគណបក្សនយោបាយប្រចាំឃុំ និងជាសមាជិកក្រុមប្រឹក្សាឃុំ អាជ្ញាធរភូមិ អង្គការមូលដ្ឋាន និង ប្រជាពលរដ្ឋនៅក្នុងឃុំបានចូលរួមពិភាក្សានៅក្នុងសិក្ខាសាលានេះ។

ប្រជាពលរដ្ឋដែលចូលរួមសិក្ខាសាលាស្ទើរតែ១០០% បានបោះឆ្នោតគាំទ្រតម្រូវការជាអាទិភាពទាំង ៥ នៅក្នុងឃុំ ដែលស្នើឱ្យក្រុមប្រឹក្សាឃុំបច្ចុប្បន្ន យកចិត្តទុកដាក់ដោះស្រាយ និង/ឬគណបក្សនយោបាយទទួលយកដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការបោះឆ្នោតឃុំ-សង្កាត់ខាងមុខ។

| តម្រូវការជាអាទិភាពទាំង៥ ក្នុងឃុំខ្ចុំក្រាំង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ |
|---|
| **១. ការសាងសង់ផ្លូវលំ**<br>• ស្នើសុំធ្វើផ្លូវក្រាលគ្រួសក្រហមចំនួន**៦ខ្សែ** ដែលមានប្រវែងសរុប១៥,០៥០ម៉ែត្រ ដោយ**ខ្សែទី១**ពីភូមិថ្នល់កែង ទៅភូមិសប់-ង៉ មានប្រវែង២៥០០ម៉ែត្រ ទទឹង៥ម៉ែត្រ **ខ្សែទី២**ពីភូមិសប់ង៉ ទៅភូមិខ្វាន មានប្រវែង២៨០០ម៉ែត្រ ទទឹង៥ម៉ែត្រ **ខ្សែទី៣**ពីភូមិខ្វាន ទៅភូមិច្របានសុខ មានប្រវែង២០៥០ម៉ែត្រ ទទឹង៥ម៉ែត្រ **ខ្សែទី៤**ពីភូមិតាសាល ទៅភូមិបាក់ត្រាចថ្មី មានប្រវែង២៥០០ម៉ែត្រ ទទឹង៥ម៉ែត្រ **ខ្សែទី៥**ពីភូមិសាមគ្គី ទៅភូមិខ្វាន មានប្រវែង៤០០០ម៉ែត្រ ទទឹង៥ម៉ែត្រ និង**ខ្សែទី៦**ស្ថិតក្នុងភូមិបៀតស្វ ទៅភូមិសាតកន្ទួត មានប្រវែង១២០០ម៉ែត្រ ទទឹង៤ម៉ែត្រ។ សូមចាប់ផ្ដើមពីឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។ |
| **២. ការធ្វើអត្តសញ្ញាណប័ណ្ណ**<br>• ស្នើសុំឲ្យមានការចុះធ្វើអត្តសញ្ញាណបណ្ណ័ជូនប្រជាពលរដ្ឋនៅទូទាំងឃុំ ឲ្យបានទាន់ពេលវេលា ព្រោះជិតដល់ពេលបោះឆ្នោតហើយ។ សូមចាប់ផ្ដើមពីឆ្នាំ២០១២នេះតទៅ។ |

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

**ទីស្នាក់ការកណ្ដាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Central Office** : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.
P.O. Box1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

**៣. ការស្នើសុំបើកវគ្គផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាល**

- សុំបើកវគ្គបណ្តុះបណ្តាលចិញ្ចឹមសត្វចំនួន៣វគ្គ អ្នកចូលរួមក្នុងវគ្គ៥០នាក់ ទៅ៦០នាក់ នៅក្នុងឃុំទាំងមូល។ សូមចាប់ផ្តើមពីឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។
- សុំបើកវគ្គផ្សព្វផ្សាយច្បាប់ដល់យុវជន យុវនារី និងប្រជាពលរដ្ឋនៅក្នុងឃុំ ស្តីអំពីច្បាប់អំពើហឹង្សាក្នុងគ្រួសារចំនួន៦វគ្គ អ្នកចូលរួមក្នុងវគ្គៗពី៥០នាក់ ទៅ៦០នាក់។ សូមចាប់ផ្តើមពីដើមឆ្នាំ២០១២នេះតទៅ។

**៤. សុំសាងសង់ទំនប់ទឹក និងស្រះទឹក**

- សុំសាងសង់ទំនប់ទឹកនៅភូមិច្រកបានសុខ មានប្រវែង៧០០ម៉ែត្រ ទទឹង៥០ម៉ែត្រ ជម្រៅ២,៥០ម។ សូមចាប់ផ្តើមពីឆ្នាំ ២០១២ តទៅបញ្ចប់ឆ្នាំ២០១៣។
- សុំជីកស្រះទឹកចំនួន២ គឺនៅភូមិសជោរមានប្រវែង១០០ម៉ែត្រ ទទឹង៥០ម៉ែត្រ និងភូមិច្រកបានសុខ មានប្រវែង១០០ម៉ែត្រ ទទឹង៧០ម៉ែត្រ។ សូមចាប់ផ្តើមពីឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។

**៥. សាលារៀន និងរោងប្រជុំភូមិ**

- សុំសាងសង់របងសាលាអនុវិទ្យាល័យអូគគី មានប្រវែង៧០ម៉ែត្រ ស្ថិតនៅក្នុងភូមិបៀតសូ។ សូមចាប់ផ្តើមពីឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៤។
- សុំសាងសង់រោងប្រជុំភូមិ១ខ្នង នៅភូមិបៀតសូ មានបណ្តោយ៧ម៉ែត្រ ទទឹង៨ម៉ែត្រ។ សូមចាប់ផ្តើមនៅឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៤។

មុនពេលបញ្ចប់សិក្ខាសាលា មានកម្មវិធីប្រគល់របាយការណ៍ ពីតម្រូវការជាអាទិភាពដល់អ្នកដឹកនាំគណបក្សនយោបាយប្រចាំឃុំ និងក្រុមប្រឹក្សាឃុំ។

លោក **ម៉ី ស៊ីម** តំណាងគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមប្រឹក្សាឃុំបានមានប្រសាសន៍ថា« លោកទទួលយកវិស័យអាទិភាពទាំងប្រាំនេះទៅដាក់ចូលក្នុងកម្មវិធីអភិវឌ្ឍន៍របស់ឃុំ និងដាក់ក្នុងកម្មវិធីនយោបាយរបស់គណបក្ស។ ហើយលោកក៏សូមអរគុណដល់អង្គការខុមហ្វ្រែលដែលរៀបចំឲ្យមានសិក្ខាសាលានេះឡើង»។

លោក **មាន ចន** តំណាងគណបក្សសមរង្ស៊ី និងជាជំទប់ទី១ បានមានប្រសាសន៍ថា «លោកទទួលយក ហើយលើកយកតម្រូវការច្រើនទៅដាក់ក្នុងកម្មវិធីគណបក្ស បើពិនិត្យឃើញថាល្អ សូមបោះឆ្នោតឲ្យគណបក្សសមរង្ស៊ីចុះ»។

លោក **ឡុត ភាព** តំណាងគណបក្សនរោត្តមរណឬទ្ធិ និងជាជំទប់ទី២ បានមានប្រសាសន៍ថា «លោកទទួលយកគោលការណ៍អាទិភាពទាំងប្រាំចំនុចនេះទៅដាក់ក្នុងគោលកាណ៍គណបក្ស ហើយបើប្រជា ពលរដ្ឋបោះឆ្នោតឲ្យលោក នោះលោកនឹងដឹកនាំឃុំឲ្យមានការអភិវឌ្ឍន៍»។

**សិក្ខាសាលានេះ មានគោលបំណង ឱ្យម្ចាស់ឆ្នោតនៅតំបន់ដាច់ស្រយាលទទួលបាន៖**

១. ការយល់ដឹងអំពីសិទ្ធិ តួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោត ក្នុងការស្វែងយល់ពីតម្រូវការជាអាទិភាពក្នុងការអភិវឌ្ឍន៍នូវមូលដ្ឋាន។

២. ផ្តល់ឱកាសឱ្យម្ចាស់ឆ្នោតចូលរួម ជជែកពិភាក្សា ដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំ សង្កាត់របស់ខ្លួន។

៣. តម្រូវការជាអាទិភាពក្នុងឃុំ សង្កាត់ ដាច់ស្រយាល នឹងត្រូវបានចងក្រងជា របាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន ជម្រុញការអនុវត្តន៍របស់ក្រុមប្រឹក្សា ឃុំ សង្កាត់ និងការដាក់បញ្ចូលតម្រូវការក្នុងកម្មវិធីនយោបាយរបស់គណបក្សសម្រាប់ការបោះឆ្នោតឃុំ សង្កាត់ ឆ្នាំ ២០១២។

សិក្ខាសាលានេះក៏បានទទួលការឧបត្ថម្ភមូលនិធិពីសហភាពអឺរុប (EU), OXFAM NOVIB, NPA និង Forum Syd

**[1]សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង ៖**

១-លោក **មួន មឿត** (មន្ត្រីផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០១២ ៩៧១ ៣២៦**

២-អ្នកស្រី **ហេង សុគន្ធា** (ជំនួយការផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០១៧ ៥៨៣ ៨៦**

**បេសកម្ម** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានពត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ពត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។

---

[1] No 091